# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## ផែនការបោះឆ្នោតដោយសុវត្ថិភាព

ខោនធី Los Angeles "ផែនការបោះឆ្នោតដោយសុវត្ថិភាព" ស្របជាមួយនឹង "ការណែនាំរបស់រដ្ឋបាលនៃការបោះឆ្នោតរបស់រដ្ឋ California ក្រោមក្របខ័ណ្ឌជម្ងឺ COVID-19 "។ ផែនការនិមួយៗត្រូវបានបង្កើតឡើងដោយមានប្រឹក្សាយោបល់ ជាមួយនឹងអាជ្ញាធរសុខាភិបាលដែលពាក់ព័ន្ធ ដោយប្រើប្រាស់ព័ត៌មានសុខាភិបាលសាធារណៈ ដែលល្អបំផុតដែលអាចរកបាន ដោយមានរាប់បញ្ចូលទាំងការណែនាំនានា ដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជម្ងឺឆ្លងអាមេរិក (CDC) និងមន្ត្រីសុខាភិបាលសាធារណៈរដ្ឋ California។



### Los Angeles មន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា/ស្មៀនខោនធី (RR/CC) នឹង ៖

- បានបង្កើតផែនការការពារទីតាំងបោះឆ្នោតដ៏ជាក់លាក់។
- ហ្វឹកហ្វឺនបុគ្គលិកពីវិធានការនានាដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-19 ដោយមានទាំងការធ្វើតេស្តពិនិត្យសុខភាពពួកគេ រកពោគសញ្ញានិងការស្នាក់នៅផ្ទះនៅពេលចាំបាច់។
- បានបង្កើតវិធានការបង្ការ និងការធ្វើតេស្តពិនិត្យសុខភាពដោយខ្លួនឯងដល់អ្នកធ្វើការ
- បានបង្កើតនិងផ្សព្វផ្សាយគោលការណ៍ណែនាំការរក្សាគម្លាតពីគ្នា។
- បានអនុវត្តពីការលាងដៃ របាំងមុខ និងវិធីសម្លាប់មេរោគ។

## សំរាប់អ្នកបោះឆ្នោត

### អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់នឹងទទួលសន្លឹកឆ្នោតបោះតាមសំបុត្រ។

L.A. ខោនធីជំរុញអោយអ្នកបោះឆ្នោតនៅផ្ទះហើយបោះឆ្នោតដោយប្រើសន្លឹកឆ្នោតផ្ញើតាមសំបុត្ររបស់គេ។ ទោះយ៉ាងនេះក្តី សម្រាប់បុគ្គលមួយចំនួន ពួកគេពេញចិត្តនឹងបោះឆ្នោតដោយផ្ទាល់។ នៅពេលបានផ្តល់ជូនការបោះឆ្នោតដោយផ្ទាល់នោះ យើងនឹងធ្វើតាមការណែនាំសុខភាពនិងសុវត្ថិភាពសាធារណៈរដ្ឋនិងខោនធីដើម្បីផ្តល់នូវបរិយាកាសបោះឆ្នោតមួយប្រកបដោយសុវត្ថិភាព។




### ព័ត៌មានអំពី កូវីដ 19 សំរាប់ការបោះឆ្នោតដោយផ្ទាល់ខ្លួន៖

- អ្នកបោះឆ្នោតគួរពាក់របាំងមុខខណៈពេលនៅមណ្ឌលបោះឆ្នោតឬពេលរង់ចាំក្នុងជួរ។
- ស្រោមដៃនិងរបាំងមុខគឺអាចរកបានសម្រាប់អ្នកចូលរួមបោះឆ្នោតប្រសិនបើគេស្នើសុំ។
- នឹងមានផ្តល់ជូនទឹកអាល់កុលលាងដៃ នៅពេលចូលនិងចេញពីមណ្ឌលបោះឆ្នោត។ ទឹកអាល់កុលលាងដៃក៏នឹងមាននៅតាមស្ថានីយ៍សំខាន់ៗក្នុងអំឡុងពេលដំណើរការបោះឆ្នោតដែរ។
- នឹងត្រូវអនុវត្តការរក្សាគម្លាតពីគ្នានៅពេលឈររង់ចាំជាជួរ និងគ្រប់ពេលវេលាទាំងអស់នៅពេលដំណើរការចូលចុះឈ្មោះ និងដំណើរការបោះឆ្នោត។
- ឧបករណ៍ ePollbooks និងឧបករណ៍គូសសន្លឹកឆ្នោតនឹងត្រូវបានធ្វើអនាម័យបន្ទាប់ពីអ្នកបោះឆ្នោតនិមួយៗប្រើហើយ។
- អ្នកបោះឆ្នោតនឹងត្រូវលើកទឹកចិត្តឲ្យចាត់វិធានការដើម្បីពន្លឿនដំណើរការបោះឆ្នោត ដើម្បីកំណត់ពេលវេលារបស់ខ្លួននៅក្នុងមណ្ឌលបោះឆ្នោត។ នេះគឺមានរាប់បញ្ចូលទាំងការបញ្ជាក់អះអាងការចុះឈ្មោះអ្នកបោះឆ្នោតជាមុន ការប្រើអន្តរកម្មសន្លឹកឆ្នោតគំរូ (ISB) ដើម្បីជ្រើសរើសជាមុននិងការនាំយកសន្លឹកឆ្នោតគំរូដើម្បីពន្លឿនការចុះឈ្មោះអ្នកបោះឆ្នោត។
- អ្នកបោះឆ្នោតនឹងត្រូវលើកទឹកចិត្តឲ្យទាញយកអត្ថប្រយោជន៍ពីការបោះឆ្នោតមុនពេលនិងការបោះឆ្នោតនៅពេលមនុស្សតិចតាមដែលអាចធ្វើទៅបាន។
- ការបោះឆ្នោតនៅតាមចិញ្ចើមថ្នល់នឹងនៅតែបន្តមានសម្រាប់អ្នកបោះឆ្នោតដែលមិនអាចចូលទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតបាន។

**បោះឆ្នោតដោយសុវត្ថិភាពនៅផ្ទះ, ធ្វើអោយគេលឺសម្លេងរបស់អ្នក**

## សម្រាប់បុគ្គលិកធ្វើការបោះឆ្នោត

### បុគ្គលិកធ្វើការបោះឆ្នោតនឹងទទួលបានការហ្វឹកហ្វឺនដើម្បីអនុវត្តនូវការណែនាំខាងក្រោមនេះ៖

- អនុវត្តតាមវិធានការណ៍បង្ការខណៈ ពេលនៅផ្ទះដើម្បី ជួយកំណត់ការរីករាលដាល COVID-19 ។
- កុំមកមជ្ឈមណ្ឌលបោះឆ្នោតប្រសិនបើត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថាមានជម្ងឺ COVID-19 រោគសញ្ញា, រឺទាក់ទងជាមួយអ្នកជំងឺវិជ្ជមានក្នុងរយៈពេល 14ថ្ងៃមុន។
- ការបញ្ជាក់អំពីការពិនិត្យដោយខ្លួនឯងដែលជាផ្នែកមួយនៃការចូលបង្ហាញខ្លួនធ្វើការប្រចាំថ្ងៃ។
- លាងដៃអោយបានញឹកញាប់ឬប្រើទឹកសម្លាប់មេរោគនៅពេលដែលគ្មានសាប៊ូនិងទឹក។
- ពាក់ឧបករណ៍ការពាររួមមានរបាំងមុខ ស្រោមមុខនិងស្រោមដៃ។
- បង្កើតបទដ្ឋានមិនប៉ះពាល់ដើម្បីអោយបុគ្គលិកការងារជៀសវាងការស្វាគមន៍មិត្តរួមការងារនិងអ្នកបោះឆ្នោតដោយមិនបាច់ប៉ះពាល់៖ "គម្លាតចាប់ផ្តើមពីសួស្តី" ។
- ធ្វើអនាម័យឲ្យបានញឹកញាប់នូវរបស់របរធ្វើការនិងកន្លែងប្រើប្រាស់ជាទូទៅ។
- ធ្វើអនាម័យ ePollbooks និងឧបករណ៍គូសសន្លឹកឆ្នោតមុនពេលចាប់ផ្តើម បន្ទាប់ពីអ្នកបោះឆ្នោតម្នាក់ៗ រាល់មួយម៉ោងម្តង និងនៅពេលបិទ។
- បង្រួមអប្បបរមាដល់ការគ្រប់គ្រងវត្ថុដែលបានប្រើរួម។
- កំណត់ចំនួនអ្នកទស្សនាដែលមិនចាំបាច់ទៅមណ្ឌលបោះឆ្នោត។
- យកចិត្តទុកដាក់ជាពិសេសក្នុងការធ្វើអនាម័យគ្រឿងបរិក្ខារមុនពេលប្រើដោយអ្នកបោះឆ្នោតដែលមានពិការភាពព្រោះពួកគេអាចធ្វើអន្តរកម្មជាមួយឧបករណ៍តាមរបៀបផ្សេងៗគ្នាហើយខ្លះអាចមានភាពងាយរងគ្រោះផ្នែកសុខភាព។ ការគ្រប់គ្រងការប្រើប្រាស់សំរាប់ឧបករណ៍បោះឆ្នោតនឹងត្រូវបានសម្អាតមុននិងក្រោយការប្រើប្រាស់នីមួយៗ។
- គម្របត្រចៀកដែលប្រើប្រាស់បានតែម្តងសម្រាប់កាសស្តាប់ត្រចៀកនឹងត្រូវបានផ្តល់ជូនហើយដាក់ជំនួសថ្មីមួយទៀតបន្ទាប់ពីការប្រើរួចនីមួយៗ។

## ប្លង់នៃមណ្ឌលបោះឆ្នោត

- ប្លង់មណ្ឌលបោះឆ្នោតផ្ទាល់ខ្លួននឹងត្រូវបានបង្កើតឡើងសម្រាប់ទីតាំងនីមួយៗដែលធានាគម្លាតពីគ្នា ៦ហ្វីត នៅទូទាំងមណ្ឌលបោះ ឆ្នោតតាមលទ្ធភាពដែលអាចធ្វើទៅបាន។
- ចរាចរថ្មើជើងដែលមានទិសតែមួយ
- ផ្លូវផ្សេងពីគ្នាសំរាប់ចូលនិងចេញតាមដែលអាចធ្វើទៅបាន។
- ទ្វារបានបើក។
- បង្អួចនឹងបើកដើម្បីបង្កើនចរាចរខ្យល់ចេញចូលតាមធ្វើទៅបាន។
- កន្លែងចុះឈ្មោះនិងម៉ាស៊ីនគូសសន្លឹកឆ្នោតត្រូវបានដាក់ដើម្បីបង្កើតចម្ងាយពីគ្នា។
- មណ្ឌលបោះឆ្នោតនីមួយៗនឹងមានស្ថានីយ៍ឈប់មួយនៅច្រកចូលដែលអ្នកបោះឆ្នោតនឹងត្រូវបានផ្តល់ជូននូវទឹកអនាម័យដៃ។ ម៉ាស់និងស្រោមដៃនឹងអាចប្រើបានសម្រាប់អ្នកបោះឆ្នោតប្រសិនបើចាំបាច់។ បុគ្គលិកបោះឆ្នោតនឹងត្រូវឈរជើងនៅទីនេះដើម្បីរំលឹកដល់អ្នក បោះឆ្នោតអំពីការប្រុងប្រយ័ត្នពិសេស។
- បើអាកាសធាតុអនុញ្ញាត ចំនួនអ្នកបោះឆ្នោតនៅទីនេះនឹងត្រូវកំណត់ ដោយការប្តូរជួររង់ចាំទៅខាងក្រៅ។

## ផ្លាកសញ្ញា

- ផ្លាកសញ្ញាដើម្បីរំលឹកអ្នកបោះឆ្នោត អ្នកសង្កេតការណ៍និងបុគ្គលិក ការងារពីគម្លាតរាងកាយ របាំងមុខ និងគំរូចរាចរណ៍ថ្មើរជើងទាន់សម័យ។
- ផ្លាកសញ្ញាដែលច្បាស់ៗ បញ្ជាក់ពីគម្លាតរាងកាយត្រឹមត្រូវ។
- ដាក់នៅផ្លូវចូលហើយនៅកន្លែងមើលឃើញយ៉ាងច្បាស់។
- និមិត្តសញ្ញាដែលមើលឃើញ (ឧ. គំនូសនៅលើកម្រាល បង់ស្អិតមានពណ៌ផ្សេងៗ ឬសញ្ញា) នឹងត្រូវបានដាក់ពង្រាយដើម្បីរំលឹកអ្នកធ្វើការនិងអ្នកបោះឆ្នោតអំពីចំងាយសមរម្យ។

## ប្រព័ន្ធផ្សព្វផ្សាយ, ប្រព័ន្ធផ្សព្វផ្សាយសង្គមនិងទំនាក់ទំនងផ្ទាល់

### យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយខោនធីនឹងរួមបញ្ចូលនូវសមាសធាតុដូចខាងក្រោម៖

- ការបោះឆ្នាតតាមសំបុត្រគឺជាជម្រើសមួយដែលមានសុវត្ថិភាពដើម្បីចៀសវាងការប៉ះពាល់ជាមួយ COVID-19 នៅពេលបោះឆ្នោត។
- មានជំរើសផ្សេងទៀតក្នុងការផ្តល់សន្លឹកឆ្នោតជំនួស ឬដើម្បីជួយអ្នកក្នុងការបោះឆ្នោតដោយមិនចាំបាច់ចូលទៅក្នុងមណ្ឌលបោះឆ្នោត រួមទាំងនីតិវិធីសម្រាប់ស្នើសុំសន្លឹកឆ្នោតជំនួស ប្រអប់ទម្លាក់សន្លឹកឆ្នោត និងការបោះឆ្នោតនៅខាងក្រៅ។
- បើអ្នកត្រូវតែចូលទៅកន្លែងបោះឆ្នោត សូម៖
  - ពាក់របាំងមុខ
  - រក្សាគម្លាតខ្លួនចំនួន 6 ហ្វីតពីមនុស្សដែលមិនមែនជាគ្រួសាររបស់អ្នក។
  - ប្រើទឹកលាងដៃសម្លាប់មេរោគមុនដល់កន្លែងចុះឈ្មោះនិងក្រោយបោះឆ្នោត។
  - ធ្វើតាមការណែនាំបន្ថែមដែលផ្តល់ជូននៅកន្លែងបោះឆ្នោត។

ផែនការនេះនឹងប្រើជាមូលដ្ឋានគ្រឹះ។ ផែនការបោះឆ្នោតដោយសុវត្ថិភាពនៃ RR/CC នឹងបន្តរីកចម្រើននិងពង្រីកនៅពេលការណែនាំនិងអនុសាសន៍ថ្មីៗចេញមក។